ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

# សេចក្តីជូនដំណឹង

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) សូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា យោងតាមកាសែត The Nation Thailand ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ អំពីការលើកឡើងរបស់ឧត្តមមន្ត្រីនៃការិយាល័យមហាអយ្យការ ដែលជាមនុស្សទី២ បន្ទាប់ពីលោកជំទាវ Angkhana Neelapaijit សមាជិកព្រឹទ្ធសភាប្រទេសថៃ ក្នុងការទទួលស្គាល់ លើករណីការប្រើប្រាស់សំឡេងរំខាន ដែលជាទម្រង់នៃការបំភិតបំភ័យ និងយាយីផ្លូវចិត្ត នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ គឺជាការរំលោភបំពានអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (CAT) ហើយវាជាការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។

គ.ស.ម.ក. សូមដកស្រង់ខ្លឹមសារ ដូចខាងក្រោមនេះ៖

"ឧត្តមមន្ត្រីនៃការិយាល័យមហាអយ្យការ ដែលសុំមិនបញ្ចេញឈ្មោះ ដោយសារភាពភ័យខ្លាចការរិះគន់ពីសំណាក់ប្រជាជនថៃ បានលើកឡើងថា ការចាក់សំឡេងបន្លាច ដូចជាសំឡេងខ្មោចក្នុងភាពយន្ត សំឡេងរថក្រោះ និងសំឡេងយន្តហោះចម្បាំង F-16 ទៅលើប្រជាជនកម្ពុជា អាចនឹងត្រូវបកស្រាយថា ជាការរំលោភកាតព្វកិច្ចក្នុងការអនុវត្តអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (CAT) ដែលប្រទេសថៃជារដ្ឋភាគី៕"

ថ្ងៃចន្ទ ៦រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥

អគារលេខ៣ ផ្លូវ VI.13 ភូមិទួលសំពៅ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
Building #3, Street VI.13, Toul Kok Village, Sangkat Toul Sangke, Khan Russey Keo, Phnom Penh Tel: (855) 23 882 065